**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.........៥០៩..........ក. ស. ភ.

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០២៦

# សេចក្ដីជូនដំណឹងលើកទី២
## ស្ដីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ
## ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ នៅចំណតផែពហុបំណងTS៣
## (របងស័ង្កសីកម្ពស់ ២,២ម៉ែត្រ ប្រវែង ៥៣ម៉ែត្រ និងជំឡើងទ្វារអូតូប្រវែង ២២ម៉ែត្រ ព្រមទាំងចល័តដើមឈើចំនួន ៧ដើម)

កំពង់ផែស្វយ័តភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា កំពង់ផែស្វយ័តភ្នំពេញនឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការលើ ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ នៅចំណតផែពហុបំណង TS៣ (របងស័ង្កសីកម្ពស់ ២,២ម៉ែត្រ ប្រវែង ៥៣ម៉ែត្រ និងជំឡើងទ្វារអូតូប្រវែង ២២ម៉ែត្រ ព្រមទាំងចល័តដើមឈើចំនួន ៧ដើម)។

កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃឯកសារពិគ្រោះថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មនៃកំពង់ផែស្វយ័តភ្នំពេញដែលមានអាសយដ្ឋានអគារ លេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...០៨......ខែ...ឧសភា....**ឆ្នាំ២០២៦** តទៅ រៀងរាល់ម៉ោងធ្វើការ (**ទូរស័ព្ទទំនាក់ទំនងលេខ ០១០ ៤៤៤ ៦៣៤**)។

កាលបរិច្ឆេទឈប់ទទួលពាក្យសំណើពិគ្រោះថ្លៃនៅ**វេលាម៉ោង**១៦:៣០**នាទី ថ្ងៃទី**១៥..**ខែ**ឧសភា**ឆ្នាំ២០២៦**។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង**១៦:៣០**នាទី ថ្ងៃទី**..១៥.....**ខែ**..ឧសភា...**ឆ្នាំ២០២៦**។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ជួន សុខេម**